# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

លេខ: ១០៤ គ.ជ.ប.ស.ស.រ

# សេចក្តីសម្រេច
## ស្តីពី
## ការផ្តល់សុពលភាព និងការដាក់ឱ្យប្រើប្រាស់បញ្ជីបោះឆ្នោតផ្លូវការ ឆ្នាំ២០២២

## គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣១៥/០០២ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣១៥/០០៣ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០១៧/០១០ ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៥/០១៥ ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០១៧/០១២ ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៥/៣២៧ ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ២០១៥ ស្តីពីការតែងតាំងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៧/១១៦៩ ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០១៧ ស្តីពីការតែងតាំងអនុប្រធាន និងសមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ជំនួសអនុប្រធាន និងសមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតដែលបានលាឈប់
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦២១/៤៩១ ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២១ ស្តីពីការតែងតាំងប្រធានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ជំនួសប្រធានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតដែលបានលាឈប់
- បានឃើញអនុក្រឹត្យលេខ ១១ អនក្រ.បក ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០២១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានឃើញសេចក្តីសម្រេចលេខ ០៤៤ គ.ជ.ប.ស.ស.រ ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២១ ស្តីពីការដាក់ឱ្យប្រើប្រាស់បទបញ្ជាផ្ទៃក្នុងរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

- បានឃើញសេចក្តីសម្រេចលេខ ១៨៨ គ.ជ.ប.ស.ស.រ ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២១ ស្តីពីការដាក់ឱ្យប្រើប្រាស់បទបញ្ជា និងនីតិវិធី សម្រាប់ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ
- បានឃើញសេចក្តីសម្រេចលេខ ២៧៦ គ.ជ.ប.ស.ស.រ ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២២ ស្តីពីការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ឆ្នាំ២០២២
- យោងស្មារតីអង្គប្រជុំគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ២០២៣

## សម្រេច

**ប្រការ១.~**

ផ្តល់សុពលភាព និងដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវបញ្ជីបោះឆ្នោត ឆ្នាំ២០២២ ក្រោយពីការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ឆ្នាំ២០២២ ដែលមានអ្នកបោះឆ្នោតសរុបចំនួន **៩,៧១០,៦៥៥ នាក់** ស្មើនឹង **៨៩.២៨ ភាគរយ** ធៀបនឹងស្ថិតិប៉ាន់ស្មានប្រជាពលរដ្ឋអាយុ ១៨ឆ្នាំឡើង ក្នុងនោះស្រីចំនួន **៥,១៦១,៩០៩នាក់** និងការិយាល័យបោះឆ្នោតសរុបចំនួន **២៣,៧៨៩ ការិយាល័យ** ។

**ប្រការ២.~**

សេចក្តីសម្រេចនេះមានអានុភាពគតិយុត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ថ្ងៃអង្គារ ២កើត ខែផល្គុន ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៣

**ជ.គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

**ប្រធាន**

ប្រាជ្ញ ចន្ទ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

**លេខ:** / **គ.ជ.ប**

## តារាងលទ្ធផលផ្លូវការនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ឆ្នាំ២០២២

| ល.រ | រាជធានី ខេត្ត | ចំនួន ឃុំ សង្កាត់ | ស្ថិតិជាន់ស្មាន | | ទិន្នន័យឆ្នាំ ២០២១ | បញ្ជីបោះឆ្នោត ឆ្នាំ២០២២ | | | |
|---|---|---|---|---|---|---|---|---|---|
| | | | ការិ. | ១៨ឆ្នាំឡើង | | សរុបរួម | ស្ត្រី | ភាគរយ | ចំនួន ការិ. |
| 01 | បន្ទាយមានជ័យ | 67 | 1,118 | 541,477 | 405,730 | 431,775 | 230,221 | 79.74% | 1,119 |
| 02 | បាត់ដំបង | 103 | 1,694 | 806,746 | 633,763 | 661,970 | 347,812 | 82.05% | 1,692 |
| 03 | កំពង់ចាម | 109 | 1,678 | 767,067 | 618,338 | 652,540 | 352,008 | 85.07% | 1,682 |
| 04 | កំពង់ឆ្នាំង | 71 | 815 | 381,195 | 343,368 | 359,698 | 194,714 | 94.36% | 818 |
| 05 | កំពង់ស្ពឺ | 88 | 1,521 | 598,385 | 571,608 | 599,245 | 320,819 | 100.14% | 1,532 |
| 06 | កំពង់ធំ | 81 | 1,146 | 507,221 | 431,776 | 456,705 | 245,169 | 90.04% | 1,152 |
| 07 | កំពត | 93 | 1,053 | 420,548 | 399,385 | 421,119 | 225,337 | 100.14% | 1,054 |
| 08 | កណ្ដាល | 127 | 1,764 | 885,256 | 775,804 | 818,459 | 434,901 | 92.45% | 1,756 |
| 09 | កោះកុង | 29 | 190 | 95,288 | 73,134 | 78,301 | 39,777 | 82.17% | 190 |
| 10 | ក្រចេះ | 48 | 593 | 243,540 | 218,776 | 231,837 | 119,389 | 95.19% | 595 |
| 11 | មណ្ឌលគិរី | 21 | 140 | 51,018 | 48,097 | 51,627 | 25,534 | 101.19% | 140 |
| 12 | រាជធានីភ្នំពេញ | 105 | 2,204 | 1,218,683 | 899,688 | 961,742 | 510,935 | 78.92% | 2,206 |
| 13 | ព្រះវិហារ | 51 | 358 | 156,901 | 143,494 | 151,191 | 77,288 | 96.36% | 357 |
| 14 | ព្រៃវែង | 116 | 1,869 | 828,039 | 715,654 | 750,836 | 408,649 | 90.68% | 1,869 |
| 15 | ពោធិ៍សាត់ | 49 | 744 | 324,122 | 287,078 | 300,328 | 159,036 | 92.66% | 744 |
| 16 | រតនគិរី | 50 | 294 | 119,583 | 109,484 | 117,657 | 59,199 | 98.39% | 295 |
| 17 | សៀមរាប | 100 | 1,521 | 779,170 | 588,553 | 618,835 | 327,696 | 79.42% | 1,521 |
| 18 | ព្រះសីហនុ | 29 | 324 | 155,701 | 136,275 | 149,807 | 75,952 | 96.21% | 326 |
| 19 | ស្ទឹងត្រែង | 34 | 245 | 94,411 | 90,968 | 97,452 | 47,688 | 103.22% | 245 |
| 20 | ស្វាយរៀង | 80 | 984 | 425,808 | 391,622 | 415,919 | 224,881 | 97.68% | 984 |
| 21 | តាកែវ | 100 | 1,591 | 693,283 | 638,627 | 668,548 | 359,952 | 96.43% | 1,595 |
| 22 | កែប | 5 | 69 | 27,979 | 26,653 | 28,198 | 14,417 | 100.78% | 69 |
| 23 | ប៉ៃលិន | 8 | 120 | 45,779 | 42,262 | 45,740 | 23,249 | 99.91% | 122 |
| 24 | ឧត្តរមានជ័យ | 24 | 405 | 170,838 | 145,976 | 151,168 | 77,111 | 88.49% | 405 |
| 25 | ត្បូងឃ្មុំ | 64 | 1,320 | 538,979 | 469,568 | 489,958 | 260,175 | 90.90% | 1,321 |
| **សរុប** | | **1,652** | **23,760** | **10,877,017** | **9,205,681** | **9,710,655** | **5,161,909** | **89.28%** | **23,789** |

ថ្ងៃអង្គារ ៧កើត ខែ អាសាឍ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ២០២៣

**ជ.គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

**ប្រធាន**

**ប្រាជ្ញ ចន្ទ**